# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ: ......... ស.ខ.ក.ក.

## សេចក្ដីអំពាវនាវ

ថ្ងៃទី១១-១២-១៣ ខែសីហា ឆ្នាំ២០១៤ខាងមុខនេះ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម រួមជាមួយ សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ មាន iCambodia_យុវជន ដើម្បីប្រជាធិបតេយ្យ, I LoveCambodia Hot News, យុវជនខ្មែរមហានគរ, យុវជនខ្មែរ ដើម្បីសន្តិភាពនិងក្លឹបយុវជនខ្មែរអន្តរជាតិនឹងរៀបចំធ្វើបាតុកម្មដង្ហែរញ្ញត្តិដាក់ជូនស្ថានទូតប្រទេសអាស៊ានប្រចាំព្រះរាជាណាចក្រកម្ពុជាទាំងអស់ ដើម្បីស្នើសុំជួយអន្តរាគមន៍ ជំរុញឲ្យរដ្ឋាភិលវៀតណាម គោរពគោលការណ៍អាស៊ានឲ្យបានពេញលេញ ក្នុងឋានៈជាប្រទេសជិតខាងល្អ ក្នុងស្មារតីមិត្តភាព និងសមធម៌។

គោលបំណងនៃការធ្វើបាតុកម្មនៅតែរក្សាជំហរឲ្យរដ្ឋាភិបាលវៀតណាមសុំទោសប្រជារាស្ត្រខ្មែរជាសាធារណៈឬទទួលស្គាល់ទឹកដីកម្ពុជាក្រោមជាអតីតទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាដដែល។

ថ្មីៗនេះ រដ្ឋាភិបាលវៀតណានៅតែបន្តប្រើប្រាស់អ្នកនាំពាក្យស្ថានទូតរបស់ខ្លួននិយាយច្រំដែលៗក្នុងន័យប្រមាថមើលងាយប្រជារាស្ត្រខ្មែរដែលយើងមិនអាចទទួលយកបានឡើយ។

សេចក្ដីដូចបានប្រគេន និងជម្រាបជូនខាងលើ ខ្ញុំព្រះករុណាខ្ញុំសូមអំពាវនាវព្រះគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនរួមឈាមទាំងអស់ ព្រះមេត្តានិងមេត្តា ជួយឧបត្ថម្ភជាថវិកា ដើម្បីបោះពុម្ពអាវយឺត, ទង់ជាតិ, ទង់សាសនា, បដា, ខិតប័ណ្ណ ជាបាយកញ្ចប់ឬជាទឹកបរិសុទ្ធតាមលទ្ធភាពដែលអាចជួយបាន ដើម្បីយើងខ្ញុំមានលទ្ធភាពរៀបចំធ្វើមហាបាតុកម្មនេះឲ្យបានជោគជ័យជូនជាតិរបស់យើង។

អង្គការ-សមាគមខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យសង្ឃឹមយ៉ាងមុតមាំទៅលើស្មារតីនៃឧត្តមគតិស្នេហាជាតិរបស់ព្រះករុណាគ្រប់ព្រះអង្គនិងបងប្អូនរួមឈាមក្នុងការជួយឧបត្ថម្ភគាំទ្រដល់ការរៀបចំធ្វើបាតុកម្មនេះទាំងស្រុង។

សូមព្រះករុណាគ្រប់ព្រះអង្គ និងបងប្អូនរួមឈាមទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤
ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**
អតីតសមាជិកព្រឹទ្ធសភា

*<u>ទូរស័ព្ទទាក់ទង</u>*

លោក ថាច់ សេដ្ឋា 093 47 47 06, 078 360 898

កញ្ញារស្មី 010 41 99 98

ឬគណនី: FTB. Thach Setha. Account number: 010-30-400-025747-5